# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## វិទ្យាស្ថានជាតិអប់រំ

# កម្មវិធីសិក្សាលម្អិត

### សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
### ផ្នែកគ្រប់គ្រងអប់រំ

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០១៩

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា មានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបានមហិច្ឆតានេះ សមត្ថភាពរបស់ពលរដ្ឋដែលមានគុណភាព មានចំណេះដឹង និងបំណិនវិទ្យាសាស្ត្របច្ចេកទេសស្របតាមទីផ្សារការងារ និងចេះត្រិះរិះពិចារណា វិភាគ ដោះស្រាយបញ្ហា ធ្វើបទបង្ហាញ ច្នៃប្រឌិតបង្កើតថ្មី និងមានបំណិនជីវិតក្នុងកិច្ចការសង្គម សេដ្ឋកិច្ច និងនយោបាយ គឺជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន។

ក្រសួងអប់រំ យុវជន និងកីឡា បន្តផ្តល់អាទិភាពខ្ពស់ដល់ការផ្តល់សេវាអប់រំប្រកបដោយសមធម៌ និងមានគុណភាពនៅគ្រប់កម្រិតសិក្សា ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ និងដល់ការអប់រំបច្ចេកទេស ក្នុងនោះក៏រួមមានកំណែទម្រង់ឧត្តមសិក្សាផងដែរ ដើម្បីឆ្លើយទៅនឹងការវិវត្តនៃបច្ចេកវិទ្យាថ្មីៗ និងទីផ្សារការងារក្នុងតំបន់ និងពិភពលោក។ លើសពីនេះ ក្រសួងក៏មានកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិនានាក្នុងការជួយគាំទ្រដល់ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះ ផ្តល់អាទិភាពដល់ការអភិវឌ្ឍគុណវុឌ្ឍិរបស់មន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ដោយផ្តោតលើបំណិនស្រាវជ្រាវអភិវឌ្ឍសមត្ថភាព និងឱកាសសិក្សាពេញមួយជីវិត ដើម្បីឆ្លើយតបនិងអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះគ្រូឧទ្ទេស និងអង្គភាពពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត និងបញ្ញាស្មារតី ក្នុងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

# មាតិកា


**មុខកថា** ...................................................... ii
**មាតិកា** ...................................................... iii
**១. ប្រវត្តិកម្មវិធីបណ្ដុះបណ្ដាល** ...................................................... 1
**២. ការពិពណ៌នាកម្មវិធីបណ្ដុះបណ្ដាល** ...................................................... 2
**៣. ចក្ខុវិស័យនៃការបណ្ដុះបណ្ដាល** ...................................................... 2
**៤. បេសកកម្មនៃការបណ្ដុះបណ្ដាល** ...................................................... 2
**៥. រចនាសម្ព័ន្ធកម្មវិធីសិក្សា** ...................................................... 2
**៦. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា** ...................................................... 5
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ចិត្តវិទ្យាអប់រំ ...................................................... 14
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ សង្គមវិទ្យាអប់រំ ...................................................... 25
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ សីលធម៌វិជ្ជាជីវៈអ្នកដឹកនាំការងារអប់រំ ...................................................... 49
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ វិធីសាស្ត្រស្រាវជ្រាវអប់រំ ...................................................... 63
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ មូលដ្ឋានគ្រឹះនៃស្ថិតិអប់រំ ...................................................... 81
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការពិនិត្យតាមដាន និងវាយតម្លៃការងារអប់រំ ...................................................... 86
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការគ្រប់គ្រងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានអប់រំ ...................................................... 98
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការអភិវឌ្ឍកម្មវិធីសិក្សា ...................................................... 106
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការអប់រំ និងគោលនយោបាយអប់រំ ...................................................... 112
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការអប់រំនៅកម្ពុជា៖ ប្រវត្តិ រចនាសម្ព័ន្ធ និង ការគ្រប់គ្រង ...................................................... 120
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ រដ្ឋបាលអប់រំ៖ ការកសាងផែនការ និង អនុវត្តផែនការ ...................................................... 129
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ...................................................... 142
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការគ្រប់គ្រងធនធានមនុស្ស ...................................................... 150
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងការបំពេញការងារក្នុងសាលា 161
កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ការបង្កើត និងអភិវឌ្ឍន៍សាលាគរុកោសល្យនៅប្រទេសជប៉ុន ...................................................... 168

## ១. ប្រវត្តិកម្មវិធីបណ្តុះបណ្តាល

ក្នុងទសវត្សទី៥០ និង៦០ ប្រទេសកម្ពុជាជាប្រទេសមួយប្រកបដោយសក្តានុពលខ្ពស់ទាំងផ្នែកអប់រំសង្គម និងសេដ្ឋកិច្ចដែលធ្វើឱ្យប្រទេសនេះមានការរីកចម្រើន និងការអភិវឌ្ឍគួរឱ្យកត់សម្គាល់ទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ ហើយជាងនេះទៅទៀតប្រព័ន្ធអប់រំនាសម័យនោះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅលើពិភពលោកផងដែរ។ ជាអកុសលប្រទេសកម្ពុជាត្រូវបានគំរាមគំហែងដោយវិបត្តិផ្ទៃក្នុង និងពីខាងក្រៅ ដែលជាហេតុនាំឱ្យប្រទេសនេះធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលអស់រយៈពេលជិត៣ទសវត្ស ដោយសារតែការរំខាន និងភាពរឹករវរទើបធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធជាតិទាំងមូលត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង។

ហេតុដូច្នេះហើយទើបប្រទេសនេះបានជួបប្រទះនូវបញ្ហារាប់មិនអស់ ដែលបង្កឡើងដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ហើយប្រព័ន្ធអប់រំក៏ត្រូវបានបំផ្លាញស្ទើរទាំងស្រុង ជាពិសេសអ្នកមានចំណេះដឹងភាគច្រើនក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត គឺជាគោលដៅនៃការកម្ទេចចោលដែលនាំឱ្យពួកគាត់ត្រូវបានគេកាប់សម្លាប់ ឬបង្ខំឱ្យភៀសខ្លួនចេញពីប្រទេស។ និយាយរួមអ្នកដែលទទួលបាននូវការអប់រំស្ទើរទាំងអស់ត្រូវបានបាត់បង់។

ការស្តារ និងការអភិវឌ្ឍវិស័យអប់រំ ដែលផ្តោតលើការលើកកម្ពស់សមត្ថភាពធនធានមនុស្សឱ្យឆ្លើយតបទៅនឹងសកលភាវូបនីយកម្មនៃចំណេះដឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើឱ្យវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ក្រសួងក៏បានបង្កើតនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០០៩-២០១៣ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ហើយក៏ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ជាតិសម្រាប់ការអប់រំទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហសវត្សរបស់ប្រទេសកម្ពុជា។

គោលនយោបាយ និងយុទ្ធសាស្ត្រដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានគេយកទៅអនុវត្តក្រោមកិច្ចសហការយ៉ាងជិតស្និតជាមួយដៃគូអភិវឌ្ឍន៍ នៅក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ហើយទទួលបាននូវការគាំទ្រទាំងថ្នាក់ជាតិ និងអន្តរជាតិ។

ក្រៅពីនេះ ក្រសួងជំរុញនិងលើកទឹកចិត្តឱ្យវិទ្យាស្ថានជាតិអប់រំបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំដោយមានការឧបត្ថម្ភទាំងផ្នែកបច្ចេកទេសនិងថវិកាពីមូលនិធិគាំទ្រវិស័យអប់រំនៅកម្ពុជា។ ក្រសួងយល់ឃើញថា ការបើកវគ្គបណ្តុះបណ្តាលនេះនឹងជួយឱ្យមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិទាំងអស់ដែលកំពុងធ្វើការក្នុងវិស័យអប់រំ ហើយត្រូវការការលើកកម្ពស់សមត្ថភាពក៏ដូចជាអភិវឌ្ឍវិជ្ជាជីវៈបន្ថែមអាចបន្តការសិក្សានៅកម្រិតខ្ពស់បាន។

## ២. ការពិពណ៌នាកម្មវិធីបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះ ត្រូវបានបង្កើតឡើងសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍លើការងាររដ្ឋបាលអប់រំ ផែនការកម្មអប់រំ ការគ្រប់គ្រងអប់រំ និងភាពជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ។ ក្រៅពីនេះ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ក៏ត្រូវបានបង្កើតឡើងសម្រាប់បំពាក់បំប៉នអ្នកសិក្សាដែលចូលសិក្សានៅក្នុងវគ្គនេះនូវជំនាញវិជ្ជាជីវៈ និងជំនាញចាំបាច់មួយចំនួនដើម្បីឱ្យក្លាយខ្លួនជាអ្នករដ្ឋបាល អ្នកធ្វើផែនការ អ្នកគ្រប់គ្រង និងអ្នកដែលមានតួនាទីផ្នែករដ្ឋបាលផ្សេងៗទៀត។

## ៣. ចក្ខុវិស័យនៃការបណ្តុះបណ្តាល

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ មានចក្ខុវិស័យឱ្យក្លាយជាកម្មវិធីសិក្សាដ៏ល្អឥតខ្ចោះមួយ ដែលមានការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិដើម្បីបង្កើនចំណេះដឹង អភិវឌ្ឍជំនាញ និងកសាងអនាគតអ្នកសិក្សាឱ្យមានសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។

## ៤. បេសកកម្មនៃការបណ្តុះបណ្តាល

អនុលោមតាមបេសកកម្មរបស់វិទ្យាស្ថានជាតិអប់រំ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ មានបេសកកម្មធ្វើការអប់រំអ្នកជំនាញប្រកបដោយសមត្ថភាព និងវិជ្ជាជីវៈដែលមានមហិច្ឆតាបម្រើក្នុងតួនាទីជាមន្ត្រីរដ្ឋបាល អ្នកធ្វើផែនការកម្ម និងអ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ក្នុងវិស័យអប់រំ។ បេសកកម្មនៃកម្មវិធីបណ្តុះបណ្តាលនេះនឹងផ្តល់ឱ្យនូវជំនាញជាច្រើនតាមរយៈសាស្ត្រាចារ្យជំនាញប្រកបដោយចំណេះដឹង និងសមត្ថភាពជំនាញក្នុងការបង្កើនឱកាសសិក្សាឱ្យបានជាអតិបរមា។ កម្មវិធីនេះបណ្តុះបណ្តាលអ្នកសិក្សាឱ្យទទួលបានចំណេះដឹងថ្មីសម្រាប់ធ្វើការអភិវឌ្ឍធនធានមនុស្ស និងសង្គម។

## ៥. រចនាសម្ព័ន្ធកម្មវិធីសិក្សា

### ៥.១. លក្ខណៈសម្បត្តិ ដើម្បីទទួលសញ្ញាបត្រ

កម្មវិធីសិក្សានេះមាន ៤៨ ក្រេឌីត (សិក្សារយៈពេល ២ ឆ្នាំ) ដែលក្នុងនោះមាន៖

(1) - ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដែលរៀបចំឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ទាក់ទិននឹងវិស័យអប់រំ និងដើម្បីអភិវឌ្ឍជំនាញក្នុងការសិក្សាស្រាវជ្រាវមាន ១៥ ក្រេឌីត (ចំនួន៥ មុខវិជ្ជា)។

(2) - មុខវិជ្ជាជំនាញវិជ្ជាជីវៈមានគោលបំណងធានាជំនាញឯកទេសនីមួយៗ ដែលមាន ២១ ក្រេឌីត (ចំនួន ៧មុខវិជ្ជា)។

(3) - មុខវិជ្ជាជ្រើសរើសមានគោលបំណងដើម្បីធ្វើឱ្យមានចំណេះដឹងទូលំទូលាយ និងជំនាញផ្សេងទៀតដែល

មាន៦ក្រេឌីត (ចំនួន ២ មុខវិជ្ជា)។

(4) - ពេលបញ្ចប់ការសិក្សា អ្នកសិក្សាត្រូវសរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលមាន ៦ ក្រេឌីត ក្នុងគោលបំណងពង្រឹងជំនាញរបស់អ្នកសិក្សាឱ្យមានសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់ណាមួយ។

## ៥.២. មុខវិជ្ជាសិក្សា

| កម្មវិធីសិក្សា | លេខកូដ | អាទិភាព | ចំនួនក្រេឌីត |
|---|---|---|---|
| **I. ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន** | | | |
| ១. ក្រមសីលធម៌ក្នុងភាពជាអ្នកដឹកនាំ | MEA 510 | ចាំបាច់ | ៣ |
| ២. ចិត្តវិទ្យា និងសង្គមវិទ្យាអប់រំ | MEA 511 | ចាំបាច់ | ៣ |
| ៣. ប្រវត្តិអប់រំ និងការអភិវឌ្ឍសង្គមនៅប្រទេសកម្ពុជា | MEA 512 | ចាំបាច់ | ៣ |
| ៤. មូលដ្ឋានគ្រឹះនៃស្ថិតិក្នុងវិស័យអប់រំ | MEA 513 | ចាំបាច់ | ៣ |
| ៥. វិធីសាស្ត្រស្រាវជ្រាវអប់រំ | MEA 514 | ចាំបាច់ | ៣ |
| | | **សរុប** | **១៥** |
| **II. មុខវិជ្ជាឯកទេសជំនាញ** | | | |
| ១.ការវិភាគប្រៀបធៀបលើស្ថានភាព និងនិន្នាការ គោលនយោបាយ ច្បាប់ និងទិសដៅអប់រំបច្ចុប្បន្ន | MEA 520 | ចាំបាច់ | ៣ |
| ២. រដ្ឋបាល ផែនការកម្ម និងមគ្គុទ្ទេសក៍អប់រំ | MEA 521 | ចាំបាច់ | ៣ |
| ៣. ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំក្នុងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ | MEA 522 | ចាំបាច់ | ៣ |
| ៤. ការអភិវឌ្ឍកម្មវិធីសិក្សា | MEA 523 | ចាំបាច់ | ៣ |
| ៥. ការគ្រប់គ្រងធនធានថវិកា និងសម្ភាររូបវន្តនៃការអប់រំ | MEA 524 | ចាំបាច់ | ៣ |
| ៦. ការគ្រប់គ្រងធនធានមនុស្ស | MEA 525 | ចាំបាច់ | ៣ |
| ៧. ការតាមដាន និងការវាយតម្លៃអប់រំ | MEA 526 | ចាំបាច់ | ៣ |
| | | **សរុប** | **២១** |
| **III. មុខវិជ្ជាជ្រើសរើស (ជ្រើសរើស ២ មុខវិជ្ជា ក្នុងចំណោម ៥ មុខវិជ្ជា)** | | | |
| ១. ការអប់រំនៅកម្ពុជា៖ រចនាសម្ព័ន្ធ និងការគ្រប់គ្រង | MEA 530 | ជម្រើស | ៣ |
| ២. ការអនុវត្តការងារគ្រប់គ្រងនៅគ្រឹះស្ថានសិក្សា | MEA 531 | ជម្រើស | ៣ |
| ៣. សិក្សាកម្រិតខ្ពស់សរសេរជំនាញវិជ្ជាជីវៈភាសាអង់គ្លេស | MEA 532 | ជម្រើស | ៣ |
| ៤. ការគ្រប់គ្រងរដ្ឋបាលអប់រំនៅគ្រឹះស្ថានសិក្សាឯកជន | MEA 533 | ជម្រើស | ៣ |
| ៥. ការធ្វើផែនការយុទ្ធសាស្ត្រ និងការវាយតម្លៃ | MEA 534 | ជម្រើស | ៣ |

| | | | |
|---|---|---|---|
| | | **សរុប** | **៦** |
| **IV. ការបញ្ចប់ការសិក្សា (និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់)** | | | |
| ១. និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | MEA 599 | ចាំបាច់ | ៦ |
| | | **សរុបរួម** | **៤៨** |

## ៥.៣. ការកំណត់ និងការវាយតម្លៃ ដើម្បីផ្ទេរក្រេឌីតសិក្សា

- អ្នកសិក្សាអាចផ្ទេរចំនួនក្រេឌីត ឬសិក្សាបន្ថែមដើម្បីអាចទទួលសញ្ញាបត្របាន។
- អ្នកសិក្សា ដែលមានបទពិសោធន៍ច្រើន ឬធ្លាប់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អាចដាក់ពាក្យសុំផ្ទេរក្រេឌីតបាន។
- ការផ្ទេរក្រេឌីតអាចផ្តល់ឱ្យអ្នកសិក្សាណា ដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ ហើយគេអាចផ្ទេរបានយ៉ាងច្រើនបំផុតត្រឹមតែ ៩ ក្រេឌីត(ចំនួន ៣ មុខវិជ្ជា)ប៉ុណ្ណោះក្នុងចំណោម ៤៨ ក្រេឌីត។
- សម្រាប់មុខវិជ្ជាសិក្សាណា ដែលគេស្វែងរកការសុំជំនួស ឬផ្ទេរក្រេឌីត អ្នកសិក្សាត្រូវតែដាក់ច្បាប់ចម្លងនៃកម្មវិធីសង្ខេបដោយភ្ជាប់ជាមួយនឹងព្រឹត្តិបត្រពិន្ទុ។
- ព័ត៌មានពាក់ព័ន្ធលម្អិត សូមទាក់ទងដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ

## ៥.៤. ចំណាត់ថ្នាក់ពិន្ទុ(GPA)

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.00 | ៩៦-១០០ | A+ | ល្អឥតខ្ចោះ |
| ៣.៦៧ | ៩០-៩៥ | A | ល្អប្រសើរណាស់ |
| ៣.៣៣ | ៨៦-៨៩ | A- | ល្អប្រសើរ |
| ៣.00 | ៨៣-៨៥ | B+ | ល្អណាស់ |
| **២.៦៧** | **៨០-៨២** | **B** | **ល្អ** |
| ២.៣៣ | ៧៦-៧៩ | B- | ល្អបង្គួរ |
| ២.00 | ៧១-៧៥ | C+ | លើមធ្យមភាគ |
| ១.៦៧ | ៦៦-៧០ | C | មធ្យម/បង្គួរ |
| ១.00 | ៦០-៦៥ | C- | ត្រូវការខំប្រឹងបន្ថែមទៀត |

## ៦. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា

**MEA 510 ក្រមសីលធម៌ក្នុងភាពជាអ្នកដឹកនាំ**

មុខវិជ្ជានេះ គឺទាក់ទងនឹងវិជ្ជាជីវៈក្នុងវិស័យអប់រំ ដែលត្រូវគេលើកយកមកសិក្សាស្រាវជ្រាវ។ អ្នកសិក្សានឹងត្រូវលើកទឹកចិត្តឱ្យធ្វើការពិចារណាថ្លឹងថ្លែងលើ ទិដ្ឋភាពវិជ្ជាជីវៈ និងបង្កើនការវាយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេអំពីវិជ្ជាជីវៈអប់រំ។ លើសពីនេះទៀតទស្សនៈស្តីពីការអភិវឌ្ឍជំនាញអប់រំបន្តនឹងត្រូវគេយកមកសិក្សាស្រាវជ្រាវ។ គោលដៅនៃមុខវិជ្ជានេះនឹងប្រកាន់ខ្ជាប់នូវគន្លងអភិវឌ្ឍការអប់រំពេញមួយជីវិត។

**MEA 511 ចិត្តវិទ្យា និងសង្គមវិទ្យាអប់រំ**

មូលដ្ឋានគ្រឹះនៃចិត្តវិទ្យា និងសង្គមវិទ្យាអប់រំត្រូវបានលើកយកមកសិក្សាស្រាវជ្រាវនៅក្នុងមុខវិជ្ជានេះដើម្បីអនុវត្តជាក់ស្តែងក្នុងវិស័យអប់រំ។ របៀបរៀន និងកត្តាផ្សេងៗដែលរំខានដល់ដំណើរការរៀនសូត្រនឹងត្រូវលើកយកមកពិភាក្សា។ គោលវិធីបង្រៀនទស្សនវិជ្ជាអប់រំ និងបញ្ហាមួយចំនួនទៀតនឹងត្រូវបានលើកយកមកពិភាក្សា និងធ្វើការសិក្សាស្រាវជ្រាវ។ អ្នកសិក្សាទាំងអស់នឹងត្រូវបានលើកទឹកចិត្តឱ្យពិភាក្សា និងបង្កើតទ្រឹស្តីអប់រំដោយខ្លួនគេផ្ទាល់។ មុខវិជ្ជានេះនឹងគ្របដណ្តប់ទៅលើការបង្កើត និងការអនុវត្តលើបញ្ញត្តិនៃទស្សនៈវិស័យសង្គមវិទ្យា ដែលទាក់ទងទៅនឹងសង្គមមូបនីយកម្ម វប្បធម៌ រចនាសម្ព័ន្ធសង្គម និងការផ្លាស់ប្តូរនានា។

**MEA 512 ប្រវត្តិអប់រំ និងការអភិវឌ្ឍសង្គមនៅប្រទេសកម្ពុជា**

មុខវិជ្ជានេះនឹងផ្តោតទៅលើការវិភាគប្រពន្ធ័អប់រំនៅកម្ពុជា រួមជាមួយការអភិវឌ្ឍសង្គមពីអតីតកាល។ វានឹងបង្ហាញពីមនោគមវិជ្ជា ទស្សនវិជ្ជា និងប្រវត្តិនៃការអប់រំក្រោមរបបអាណានិគមនិយមបារាំង សង្គមរាស្ត្រនិយម សាធារណៈរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) និងការអភិវឌ្ឍសង្គមក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩។

**MEA 513 មូលដ្ឋានគ្រឹះនៃស្ថិតិក្នុងវិស័យអប់រំ**

មុខវិជ្ជានេះ នឹងរំឭកឡើងវិញនូវបញ្ញត្តិសំខាន់ៗនៃគណិតវិទ្យា ចំពោះស្ថិតិ ការជ្រើសរើសសំណាកគំរូ និងការប្រើប្រាស់កុំព្យូទ័រ។ ស្ថិតិពិពណ៌នា ការគណនាពិន្ទុ សំណាកគំរូប្រូបាប តម្រែតម្រង់លីនេអ៊ែ ណែនាំពីស្ថិតិសន្និដ្ឋាន និងតេស្តនៃសារៈសំខាន់ជាមូលដ្ឋាននឹងត្រូវពិភាក្សាក្នុងការសិក្សានេះ។

**MEA 514** **វិធីសាស្ត្រស្រាវជ្រាវអប់រំ**

មុខវិជ្ជានេះ នឹងផ្តោតលើមូលដ្ឋានគ្រឹះវិធីសាស្ត្រស្រាវជ្រាវអប់រំ ដែលរួមមានការស្រាវជ្រាវ តាមបែបគុណភាព និងបរិមាណ ការជ្រើសរើសសំណាកគំរូ ក្រមសីលធម៌ ឧបករណ៍ស្រាវជ្រាវ និងលទ្ធផលអាចយកជាការបាន។ គោលបំណងនេះ ដើម្បីបង្កើនសមត្ថភាពក្នុងការវិភាគត្រិះរិះពិចារណា និងដើម្បីពង្រឹងយុទ្ធសាស្ត្រឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងការអប់រំ។ ការកំណត់ និងការវាយតម្លៃទៅលើបញ្ហាស្រាវជ្រាវ ការប្រើប្រាស់ធនធានបណ្ណាល័យ ការប្រមូលទិន្នន័យ និងការសរសេរ របាយការណ៍ស្រាវជ្រាវ ជាចំណុចសំខាន់ក្នុងមុខវិជ្ជានេះ។ អ្នកសិក្សាអាចៈ

- កំណត់វិធីសាស្ត្រស្រាវជ្រាវបែបបបរិមាណ និងគុណភាព ភាពស្រដៀង និងខុសគ្នា និងការលើកភស្តុតាងមួយចំនួនមកប្រើប្រាស់នៅក្នុងទម្រង់នៃការស្រាវជ្រាវនីមួយៗ។
- វិភាគបញ្ហាស្រាវជ្រាវ និងទាញចេញនូវសំណួរស្រាវជ្រាវពាក់ព័ន្ធទៅនឹងការអប់រំសម្រាប់ធ្វើការសង្កេត។
- ប្រើប្រាស់គោលការណ៍ស្រាវជ្រាវដើម្បីបង្កើតការចង្អុលបង្ហាញអំពីសំណួរស្រាវជ្រាវ។
- កំណត់ និងជ្រើសរើសទ្រឹស្ត្រី និងបញ្ញត្តិជាមូលដ្ឋានសម្រាប់បញ្ហាស្រាវជ្រាវ។
- រៀបចំគម្រោងសិក្សាស្រាវជ្រាវ។

**MEA 520** **ការវិភាគប្រៀបធៀបលើស្ថានភាព និងនិន្នាការ គោលនយោបាយ ច្បាប់ និងទិសដៅអប់រំបច្ចុប្បន្ន**

មុខវិជ្ជានេះអ្នកសិក្សានឹងត្រូវបានលើកទឹកចិត្តឱ្យពិនិត្យ និងពិភាក្សាលើបញ្ហាទាំងឡាយ ដែលទាក់ទងក្នុងវិស័យអប់រំបច្ចុប្បន្ន។ មុខវិជ្ជានេះ សិក្សាពីច្បាប់ស្តីពីការអប់រំ ច្បាប់រដ្ឋបាល ដែលនាក់ទិនទៅនឹងកិច្ចការអប់រំ ។ ជាងនេះទៅទៀត ស្ថានភាព និងនិន្នាការអប់រំបច្ចុប្បន្នដូចជាមុខវិជ្ជា គោលនយោបាយ ផ្នែកទ្រឹស្តីសង្គម និងការអនុវត្តជាក់ស្តែង នឹងត្រូវបានលើកយកមកសិក្សា។

**MEA 521** **រដ្ឋបាល ផែនការកម្ម និងមគ្គុទ្ទេសក៍អប់រំ**

មុខវិជ្ជានេះ មានប្រធានបទដូចខាងក្រោម ត្រូវបានលើកយកមកពិភាក្សាៈ

- សាលារៀនជាប្រព័ន្ធនៃសង្គមមួយ
- ហ្វឹកហ្វឺនគរុកោសល្យក្នុងការរៀននិងបង្រៀន
- រចនាសម្ព័ន្ធគ្រឹះស្ថានសិក្សា
- កាតព្វកិច្ចរបស់បុគ្គលម្នាក់ៗនៅក្នុងសាលារៀន

- វប្បធម៌ និងបរិយាកាសសាលារៀន
- ការគ្រប់គ្រង និងគោលនយោបាយសាលារៀន
- បរិស្ថានខាងក្រៅសាលារៀន
- ប្រសិទ្ធភាព និងគុណភាពសាលារៀន
- ការសំរេចចិត្តនៅក្នុងសាលារៀន
- ការទំនាក់ទំនងនៅក្នុងសាលារៀន និង
- ភាពជាអ្នកដឹកនាំនៅក្នុងសាលារៀន

**MEA 522 ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំក្នុងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ**

ការបង្កើតបរិយាកាសសិក្សា និងការបង្រៀនជោគជ័យសម្រាប់សិស្ស និងបុគ្គលិកគឺជាប្រធានបទយ៉ាងសំខាន់នៅក្នុងមុខវិជ្ជានេះ។ មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីត្រួតពិនិត្យលើការគ្រប់គ្រង ការបង្រៀន បច្ចេកទេសគ្រប់គ្រង និងជំនាញផ្សេងៗទៀតដែលចាំបាច់ក្នុងការចាត់ចែង និងវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល។ វាផ្ដោតផងដែរលើវិធីសាស្ត្រសំខាន់ៗនៃការគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការលើកកម្ពស់ការបង្រៀនតាមរយៈការប្រមូលទិន្នន័យ ការវាយតម្លៃជាដំណាក់ ការវាយតម្លៃបញ្ចប់លើស្តង់ដារនៃការបង្រៀន និងការអភិវឌ្ឍបុគ្គលិក។ គេរំពឹងថាសិក្ខាកាមនឹងមានទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហគមន៍ព្រោះពួកគេជាអ្នកបង្កើតស្តង់ដារសិស្ស វាយតម្លៃសិស្សនិងជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា ដឹកនាំការបង្រៀនឱ្យមានប្រសិទ្ធភាពនិងលើកកម្ពស់បរិយាកាសសាលារៀនមួយសម្រាប់ការសិក្សា។

វគ្គនេះលើកឡើងអំពីសារៈសំខាន់នៃការប្រតិបត្តិការកុំព្យូទ័រ ការបញ្ចូលបច្ចេកវិទ្យាកុំព្យូទ័រក្នុងបរិយាកាសសិក្សា ទ្រឹស្តីនៃការរៀន ឬគម្រោងធ្វើបទបង្ហាញដោយប្រើបច្ចេកវិទ្យា និងការប្រើប្រាស់បទបង្ហាញ និងកម្មវិធីកុំព្យូទ័រពាក់ព័ន្ធ។ ក្រោយបញ្ចប់មុខវិជ្ជានេះដោយជោគជ័យ អ្នកសិក្សានឹងអាចៈ

- បង្កើនចំណេះដឹងផ្នែកប្រតិបត្តិការកុំព្យូទ័រ តបណ្តាញ អ៊ីនធឺណែតនិងគេហទំព័រ
- ប្រើប្រាស់បច្ចេកវិទ្យាពាក់ព័ន្ធក្នុងការបង្កើតសម្ភារឧបទ្ទេសសិក្សាផ្សេងៗ
- ពណ៌នាអំពីវិធីសាស្ត្របង្រៀនថ្មីៗ ការសិក្សាស្រាវជ្រាវ និងការវាយតម្លៃការអនុវត្តដែលមានទំនាក់ទំនងទៅនឹងការប្រើប្រាស់កុំព្យូទ័រ និងធនធានបច្ចេកវិទ្យាក្នុងកម្មវិធីសិក្សា
- ពិភាក្សា និងវិភាគបញ្ហានានា ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់កុំព្យូទ័រក្នុងវិស័យអប់រំ រួមមានបញ្ហាសុវត្ថិភាព សមភាព កម្មសិទ្ធិបញ្ញា និងក្រមសីលធម៌វិជ្ជាជីវៈនៃការប្រើប្រាស់អ៊ីនធឺណែតក្នុងថ្នាក់រៀន។ ការបង្កើតកម្មវិធីប្រើប្រាស់បច្ចេកវិទ្យានេះមាន

ឡើងអាស្រ័យទៅលើស្ថានភាពបណ្តុះបណ្តាលជាក់ស្តែង

- រៀបចំតាក់តែង ឬអភិវឌ្ឍកម្មវិធីដោយប្រើបច្ចេកវិទ្យាសម្រាប់ធ្វើបទបង្ហាញ។

**MEA 523 ការអភិវឌ្ឍកម្មវិធីសិក្សា**

ការអភិវឌ្ឍកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាត្រូវបានលើកយកមកពិភាក្សានៅក្នុងមុខវិជ្ជានេះ។ វាផ្តោតសំខាន់លើការធ្វើផែនការការរៀបចំកម្មវិធីសិក្សា ក៏ដូចជាការអភិវឌ្ឍមុខវិជ្ជានីមួយៗ និងទំនាក់ទំនងរបស់វាទៅនឹងបេសកកម្ម កម្មវត្ថុ និងលទ្ធផល។ មុខវិជ្ជានេះនឹង៖

(i) វិភាគបញ្ហាពីនិន្នាការនានាសម្រាប់រៀបចំ និងធ្វើផែនការកម្មវិធី

(ii) វាយតម្លៃផលប៉ះពាល់នៃភ្នាក់ងារត្រួតពិនិត្យ និងផ្តល់គុណភាពលើការរៀបចំកម្មវិធីសិក្សា

(iii) ពិពណ៌នាពីសារៈសំខាន់នៃទ្រឹស្តីក្នុងការធ្វើផែនការ និងការរៀបចំកម្មវិធីសិក្សា

(iv) វិភាគទៅលើជំនឿ និងគុណតម្លៃនៃការអប់រំជាមូលដ្ឋានព្រមទាំងផលប៉ះពាល់

(v) ពិពណ៌នាទ្រឹស្តីនៃការសិក្សាផ្សេងៗ និងការជះឥទ្ធិពលរបស់វាលើការធ្វើផែនការ និងការរៀបចំកម្មវិធីសិក្សា ។

**MEA 524 ការគ្រប់គ្រងធនធានថវិកា និងសម្ភារៈរូបវន្តនៃការអប់រំ**

លំនាំនៃការរៀបចំ ការវិភាគ និងការត្រួតពិនិត្យថវិកា គឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើចរាចរហិរញ្ញវត្ថុរបស់ស្ថាប័ន អង្គភាព ឬសេវាកម្មណាមួយ ។ បញ្ញត្តិនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុក៏ដូចជាគោលការណ៍សេដ្ឋកិច្ចជាមូលដ្ឋានត្រូវបានគេយកមកអនុវត្ត។ មុខវិជ្ជានេះនឹងផ្តោតសំខាន់លើ៖

(i) ការរៀបចំ និងត្រួតពិនិត្យថវិកា ដូចជាការវិភាគលើការប្រែប្រួលថវិកា និងយុទ្ធសាស្ត្រនានាសម្រាប់ដោះស្រាយនូវការប្រែប្រួលទាំងនោះ។ បង្កើតយុទ្ធសាស្ត្រសម្រាប់ការត្រួតពិនិត្យថវិកា និងការបង្កើតថវិកាជាសមាសភាគមួយនៃការធ្វើផែនការអាជីវកម្ម។

(ii) ការវិភាគ ការអនុវត្តហិរញ្ញវត្ថុ មានដូចជា វាយតម្លៃការអនុវត្តហិរញ្ញវត្ថុរបស់ស្ថាប័ន ឬការធ្វើអាជីវកម្មណាមួយដោយប្រើប្រាស់ តារាងតុល្យភាព របាយការណ៍ចំណូលចំណាយរបាយការណ៍លំហូរសាច់ប្រាក់ និងសមាមាត្រហិរញ្ញវិត្ថុ ។

**MEA 525 ការគ្រប់គ្រងធនធានមនុស្ស**

មុខវិជ្ជានេះពិនិត្យពីតួនាទីរបស់អ្នកជំនាញការធនធានមនុស្ស ដែលជាដៃគូរយុទ្ធ

សាស្ត្រក្នុងការគ្រប់គ្រងស្ថាប័ន ឬអង្គភាពនានាក្នុងពេលបច្ចុប្បន្ន។ មុខងារសំខាន់ៗដូចជាៈ ការតែងតាំង ការជ្រើសរើស ការអភិវឌ្ឍ ការវាយតម្លៃ សំណងឬការប៉ះប៉ូវ និងទំនាក់ទំនងពលកម្មត្រូវបានត្រួតពិនិត្យ។ ផលប៉ះពាល់នានានៃច្បាប់ និងបរិយាកាសសកលត្រូវ បានវាយតម្លៃ ហើយបញ្ហាថ្មីៗដូចជាៈ ការបណ្ដុះបណ្ដាលផ្សេងៗ ការបំពារបំពានផ្លូវភេទ និង ការកើនឡើងនៃប្រាក់ចំណូលត្រូវបានវិភាគ។ ជម្រើសរបស់នយោជកក្នុងការអនុវត្តដ៏ល្អបំផុតត្រូវបានលើកមកពិភាក្សា។ លើសពីនេះទៅទៀត មុខវិជ្ជានេះក្ដោបលើនីតិកម្ម ការវិភាគការងារ និងការរៀបចំផែនការធនធានមនុស្ស ដោយផ្ដោតលើការផ្ដល់បុគ្គលិកឱ្យស្ថាប័ន ឬអង្គភាពមួយឱ្យត្រូវនឹងប្រភេទ និងចំនួននៃនយោជិកដែលខ្លួនត្រូវការនៅពេលណាមួយ។ ប្រធានបទនានាអាចរួមបញ្ចូលការណែនាំបុគ្គលិកថ្មី ការបណ្ដុះបណ្ដាលអក្ខរកម្មដំបូង ការអប់រំសម្រាប់អ្នកប្រតិបត្តិកម្រិតខ្ពស់ កម្មវិធីការអភិវឌ្ឍអាជីពដើម្បីបង្កើនការងារជាក្រុម ការអភិវឌ្ឍស្ថាប័ន ឬអង្គភាពក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្ដូរសំណង និង ដំណើរការលើកិច្ចព្រមព្រៀងតម្លៃ។

**MEA 526** ការតាមដាន និងការវាយតម្លៃការអប់រំ

មុខវិជ្ជានេះមានគោលបំណងត្រួតពិនិត្យទៅលើការបង្រៀន បច្ចេកទេសចាត់ចែង និងជំនាញផ្សេងៗទៀតដែលចាំបាច់ក្នុងការគ្រប់គ្រង និងវាយតម្លៃកម្មវិធីសិក្សា។ វាក៏ផ្ដោតផងដែរទៅលើការតាមដាន និងវាយតម្លៃពីរបៀបគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការកែលម្អការបង្រៀនតាមរយៈលទ្ធផលនៃការសិក្សា ការវាយតម្លៃជាដំណាក់ៗ ការវាយតម្លៃចុងក្រោយតាមស្ដង់ដារ និងការអភិវឌ្ឍបុគ្គលិក។

អ្នកសិក្សាត្រូវបានរំពឹងទុកថាអាចបង្កើតទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហគមដូចជាការអភិវឌ្ឍយន្តការវាយតម្លៃសិស្ស ជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា បង្កើនគុណភាពបង្រៀនឱ្យមានប្រសិទ្ធភាព និងជំរុញឱ្យមានបរិយាកាសសិក្សាល្អក្នុងសាលារៀន។

**MEA 530** **ការអប់រំនៅកម្ពុជាៈ រចនាសម្ព័ន្ធ និងការគ្រប់គ្រង**

មុខវិជ្ជានេះ ផ្ដោតសំខាន់លើការពិភាក្សាអំពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងវិស័យអប់រំនៅចំណោះទូទៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ អ្នកសិក្សាត្រូវលើកទឹកចិត្តដើម្បីរុករកឯកសារដែលមានស្រាប់ និងសៀវភៅសិក្សាលើមាតិកា ដែលទាក់ទងនឹងកម្មវិធីសិក្សាបច្ចុប្បន្ន រួមមានៈ

- គោលនយោបាយ
- វិធីសាស្ត្របង្រៀន
- ការត្រួតពិនិត្យ

- ការចាត់ចែង ការវាយតម្លៃ និងអភិបាលកិច្ចជាប្រចាំ។

វិសាលភាពនៃខ្លឹមសារមេរៀននេះត្រូវតែកំណត់ឱ្យបានច្បាស់លាស់ស្ដីពីអភិបាលកិច្ចល្អនៅគ្រប់ភូមិសិក្សា និងគ្រឹះស្ថានឧត្ដមសិក្សាគ្រប់កម្រិតរួមមានៈ មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។

មុខវិជ្ជានេះ ជាមគ្គុទ្ទេសក៏ដ៏សំខាន់សម្រាប់កំណត់លក្ខណៈវិនិច្ឆ័យពីដំណើរការទទួលស្គាល់គុណភាពអប់រំ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

**MEA 531 ការអនុវត្តការងារគ្រប់គ្រងនៅគ្រឹះស្ថានសិក្សា**

មុខវិជ្ជានេះផ្តោតសំខាន់ទៅលើអ្នកគ្រប់គ្រងសាលារៀន និងអ្នកដែលទទួលបន្ទុកការគ្រប់គ្រងផ្សេងៗទៀត។ គោលបំណងសំខាន់គឺពង្រឹងការយល់ដឹងឱ្យស៊ីជម្រៅអំពីទស្សនវិស័យនៃការគ្រប់គ្រងតាមរយៈការបំពាក់នូវជំនាញច្បាស់លាស់ និងជំរុញពួកគេឱ្យបង្កើតផែនការគ្រប់គ្រងដោយខ្លួនឯងសម្រាប់ឆ្នាំសិក្សានីមួយៗ។ អ្នកសិក្សាទាំងអស់នឹងបញ្ចេញនូវជំនាញនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរួមមាន ទម្លាប់ក្នុងការអនុវត្ត ការបង្កើតយន្តការក្នុងការវាយតម្លៃ បង្កើតផែនការវាយតម្លៃប្រចាំឆ្នាំដោយប្រើកម្រងព័ត៌មានសម្រាប់ប្រមូលចងក្រងភស្តុតាងសកម្មភាពអនុវត្ត ផ្តល់វគ្គបំប៉ន និងបង្កើតផែនការអនុវត្តនៅពេលអនាគត។

**MEA 532 សិក្សាកម្រិតខ្ពស់សរសេរជំនាញវិជ្ជាជីវៈភាសាអង់គ្លេស**

មុខវិជ្ជានេះមានគោលបំណងលើកកម្ពស់សមត្ថភាពក្នុងការសរសេរជាភាសាអង់គ្លេសចំពោះអ្នកសិក្សាទាំងឡាយ ដែលមានឧបនិស្ស័យក្នុងការសរសេរអត្ថបទស្រាវជ្រាវផ្សេងៗ។ វាចាប់ផ្តើមពីការរំលឹកមូលដ្ឋានគ្រឹះនៃវេយ្យាករណ៍ និងជំនាញក្នុងការសរសេរ។ វាក៏គ្រប ដណ្តប់ទៅលើគន្លឹះជាច្រើនផងដែរ ក្នុងការរៀបចំកម្រងសំណួរ ការប្រមូល និងវិភាគទិន្នន័យ និងរបៀបនៃការសរសេរនិក្ខេបបទ។

**MEA 533 ការគ្រប់គ្រងរដ្ឋបាលអប់រំនៅគ្រឹះស្ថានសិក្សាឯកជន**

មុខវិជ្ជានេះផ្តោតទៅលើការបរិយាយពីការបង្កើតការគ្រប់គ្រងជាប្រព័ន្ធ និងអភិបាលកិច្ចក៏ដូចជាយន្តការនៃការគ្រប់គ្រងសាលា និងគ្រឹះស្ថានសិក្សាឯកជន។ អ្នកសិក្សាត្រូវបានជំរុញឱ្យពិភាក្សាលើប្រធានបទដែលទាក់ទងទៅនឹងសាលាឯកជនរួមមានរចនាសម្ព័ន្ធ មនុស្ស សិទ្ធិអំណាច គោលនយោបាយ ប្រសិទ្ធភាព គុណភាព សេចក្តីសម្រេច ទំនាក់ទំនង ភាពជាអ្នកដឹកនាំ និងបរិយាកាសវប្បធម៌ក្នុង និងក្រៅសាលា។

**MEA 534 ការធ្វើផែនការយុទ្ធសាស្ត្រ និងការវាយតម្លៃ**

មុខវិជ្ជានេះ គ្របដណ្តប់ទៅលើជំហ៊ានសំខាន់ៗក្នុងលំនាំនៃការធ្វើផែនការ និងការអនុវត្ត ជំហ៊ានសំខាន់ៗទាំងនោះ ព្រមទាំងពិភាក្សាអំពីដែនកំណត់នៃការធ្វើផែនការផងដែរ។

ក្រោយការបញ្ចប់ដោយជោគជ័យនៃមុខវិជ្ជានេះ អ្នកសិក្សានឹងអាចៈ

- ចេះគ្រប់គ្រង ត្រួតពិនិត្យ ចាត់ចែង និងធ្វើផែនការកម្ម តាមពេលវេលា។
- ប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសក្នុងការគ្រប់គ្រង។
- អនុវត្តការគ្រប់គ្រងទៅតាមតួនាទីផ្សេងៗបាន។
- ប្រមើលមើលឡើងវិញ និងវាយតម្លៃលើលក្ខខណ្ឌនៃការគ្រប់គ្រងទៅតាមផ្នែកនីមួយៗ។
- មានចរិកលក្ខណៈ និងឥរិយាបថជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព។
- ក្លាយជាគ្រូបង្រៀនគម្រូ ឬនាយក/ នាយិកា ប្រកបដោយប្រសិទ្ធភាព។
- យល់ និងចេះវិភាគចរិកលក្ខណៈរបស់មន្ត្រីនៅក្រោមឱវាទ។

គ្រប់គ្រងធនធានមនុស្សនិងធនធានសម្ភារៈរបស់អង្គភាពឱ្យមានប្រសិទ្ធភាព។

**MEA 599 និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

អ្នកសិក្សានឹងត្រូវធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទដែលទទួលបានការឯកភាពក្នុងមុខវិជ្ជាពាក់ព័ន្ធ ព្រមទាំងសរសេរនិក្ខេបបទ ឬរបាយការណ៍សិក្សាស្រាវជ្រាវ។ ការត្រួតពិនិត្យជាប្រចាំត្រូវបានរៀបចំធ្វើឡើង។ ដូចបានលើកឡើងរួចហើយ អ្នកសិក្សាគួរតែយល់ដឹងអំពីព័ត៌មានដូចខាងក្រោមមុនពេលសរសេរនិក្ខេបបទៈ

- និក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវ អ្នកសិក្សាត្រូវគេរំពឹងថាបានរៀនចប់មុខវិជ្ជាចំនួន ៤២ ក្រេឌីតជាមួយនឹងមធ្យមភាគពិន្ទុ(GPA)យ៉ាងតិច ២.៦៧
- ចំពោះប្រធានបទនៃនិក្ខេបបទ និងគោលគំនិតសំខាន់ៗសម្រាប់គម្រោងសិក្សាស្រាវជ្រាវដែលទទួលបានការឯកភាពពីសាស្ត្រាចារ្យត្រួតពិនិត្យគឺជាការចាំបាច់ជាមុន (ព័ត៌មានលម្អិត សូមអានសៀវភៅព័ត៌មានអំពីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់)
- ការប្រមូលព័ត៌មានសម្រាប់សរសេរនិក្ខេបបទ អ្នកសិក្សាម្នាក់ៗត្រូវធានាថា របាយការណ៍សិក្សាស្រាវជ្រាវ ឬនិក្ខេបបទរបស់ខ្លួនត្រូវសរសេរឡើងជាបន្តបន្ទាប់ជាមួយការណែនាំ និងរិះគន់ពីសាស្ត្រាចារ្យត្រួតពិនិត្យ
- សេចក្តីព្រាងនៃនិក្ខេបបទត្រូវតែដាក់ជូនគណៈកម្មការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដើម្បីធ្វើការវាយតម្លៃ រិះគន់ និងលើកជាសំណូមពរសម្រាប់កែលម្អក្រោយទទួលបានការឯកភាពពីគណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

និងការការពារ ឬការធ្វើបទបង្ហាញនិក្ខេបបទនោះនឹងត្រូវបានរៀបចំឡើងសម្រាប់អ្នកសិក្សាម្នាក់ៗ។

# មុខវិជ្ជា

## សម្រាប់បណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

| មុខវិជ្ជា | | ចំនួនម៉ោងបណ្តុះបណ្តាលតាមត្រីមាស | | ម៉ោង | ក្រឌីត |
|---|---|---|---|---|---|
| | | ត្រីមាសទី១ (វិច្ឆិកា-មីនា) | ត្រីមាសទី២ (ឧសភា-សីហា) | | |
| ១ | ចិត្តវិទ្យាអប់រំ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ២ | សង្គមវិទ្យាអប់រំ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ៣ | ក្រមសីលធម៌អ្នកដឹកនាំអប់រំ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ៤ | វិធីសាស្ត្រស្រាវជ្រាវអប់រំ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ៥ | ស្ថិតិអប់រំ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ៦ | ពិនិត្យតាមដាន និងវាយតម្លៃអប់រំ | | ៣ម៉ x ១៥ស | ៤៥ | ៣ |
| ៧ | ការគ្រប់គ្រងការបង្រៀន និងបច្ចេកវិទ្យាព័ត៌មានអប់រំ | | ៣ម៉ x ១៥ស | ៤៥ | ៣ |
| ៨ | ការអភិវឌ្ឍកម្មវិធីសិក្សា | | ៣ម៉ x ១៥ស | ៤៥ | ៣ |
| ៩ | ការអប់រំ និងគោលនយោបាយអប់រំ | | ៣ម៉ x ១៥ស | ៤៥ | ៣ |
| ១០ | ការអប់រំនៅកម្ពុជា៖ ប្រវត្តិ រចនាសម្ព័ន្ធ និងការគ្រប់គ្រង | | ៣ម៉ x ១៥ស | ៤៥ | ៣ |
| ១១ | រដ្ឋបាលអប់រំ៖ ការកសាងផែនការ និងអនុវត្តផែនការ | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ១២ | ការគ្រប់គ្រងថវិកា | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ១៣ | ការគ្រប់គ្រងធនធានមនុស្ស | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ១៤ | ការគ្រប់គ្រងការបំពេញការងារក្នុងសាលា | ៣ម៉ x ១៥ស | | ៤៥ | ៣ |
| ១៥ | ការបង្កើត និងអភិវឌ្ឍន៍សាលាគរុកោសល្យនៅប្រទេសជប៉ុន | ៣ម៉ x ១៥ស | | ៤៥ | ៣ |

# កម្មវិធីសិក្សាលម្អិតមុខវិជ្ជា៖ ចិត្តវិទ្យាអប់រំ
# សម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

## ១. សេចក្តីផ្តើម

វគ្គសិក្សានេះផ្តោតលើចិត្តវិទ្យាអប់រំ ជាផ្នែកមួយនៃការរៀបចំវិជ្ជាជីវៈសម្រាប់ការបង្រៀន ឬអ្នកប្រើប្រាស់ចិត្តសាស្ត្រក្នុងដំណើរការបង្រៀន។ ខ្លឹមសារនៃឯកសារនេះ មានសារៈសំខាន់សម្រាប់អ្នកចាប់អារម្មណ៍និងមានការព្រួយបារម្ភអំពីការសិក្សានិងការអប់រំ។ ខ្លឹមសារនៃវគ្គសិក្សានេះ សង្កត់ធ្ងន់ដំបូងនឹងផ្តោតលើអ្វីដែលជាចិត្តវិទ្យាអប់រំបកស្រាយពន្យល់ពីទំនាក់ទំនងនៃការអភិវឌ្ឍរូបរាងកាយ និងចិត្តចលភាពរបស់កុមារតាមដំណាក់កាល និងវិធីសាស្ត្រអប់រំអាកប្បកិរិយានិងការអភិវឌ្ឍការយល់ដឹងនិងភាសាត្រូវបានរួមបញ្ចូលផងដែរ។ នៅក្នុងវគ្គសិក្សានេះយើងនឹងបង្ហាញពីផលប៉ះពាល់និងការអនុវត្តនៃការស្រាវជ្រាវលើវិធីសាស្ត្រអភិវឌ្ឍន៍អាកប្បកិរិយា និងវិធីសាស្ត្រក្នុងការលើកកម្ពស់អាកប្បកិរិយាជួយកុមារអភិវឌ្ឍជំនាញសង្គមដោះស្រាយនឹងអាកប្បកិរិយាដែលមិនចង់បាន និងទ្រឹស្តីនៃទ្រឹស្តី Piaget និង Vygotsky សម្រាប់គ្រូតាមរយៈគម្រោងគ្រប់គ្រងគម្រោងនៅសាលារៀន។ ខ្លឹមសារនៃវគ្គសិក្សានឹងឆ្លុះបញ្ចាំងពីការអនុវត្តផ្លូវចិត្តដ៏ចិត្តវិទ្យាអប់រំសំខាន់នៅក្នុងវិស័យអប់រំ។

## ២. គោលបំណង

វគ្គសិក្សានេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ចំណេះដឹងនៃការយល់ដឹងពីបាតុភូតមនុស្សដែលរួមបញ្ចូលទាំងការអភិវឌ្ឍរាងកាយ និងផ្លូវចិត្ត។ ចំណុចដ៏សំខាន់មួយនៃចិត្តវិទ្យាអប់រំ គឺអ្នកអប់រំត្រូវយល់ដឹងពីរបៀបនៃការរួមបញ្ចូលគ្នារវាងតម្រូវការរបស់សិស្សក្នុងការបង្រៀននិងរៀន ដើម្បីបង្កើតបរិយាកាសសិក្សាប្រកបដោយភាពសប្បាយរីករាយ និងប្រសិទ្ធភាព។ នៅពេលបញ្ចប់វគ្គសិក្សានេះ អ្នកសិក្សានឹង៖

- ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពិតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀននិងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ
- អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀន និងអប់រំ យ៉ាងមានប្រសិទ្ធភាព
- យកទ្រឹស្តីទាំងនេះ ទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀន និងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។

| | |
|---|---|
| **វិជ្ជាសម្បទា** | – ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ។ |
| **បំណិនសម្បទា** | – អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀន និងអប់រំ យ៉ាងមានប្រសិទ្ធភាព។ |
| **ចរិយាសម្បទា** | – យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ |

## ៣. គោលគំនិតសំខាន់ៗ

អ្នកសិក្សា នឹងទទួលបានការយល់ដឹងទូលំទូលាយហើយត្រូវតែមានវត្តមាននៅម៉ោងសិក្សានិងចូលរួមក្នុងសកម្មភាពពិភាក្សាក្នុងថ្នាក់។ ដូចគ្នានេះផងដែរពួកគាត់តម្រូវឱ្យបំពេញកិច្ចការស្រាវជ្រាវ ការរៀបចំបទបង្ហាញ និងត្រូវគល់កិច្ចការឱ្យបានឆាប់ឬទាន់ពេលវេលាហើយពួកគេមិនត្រូវខកខានការប្រលងត្រួតពិនិត្យនិងការប្រឡងបញ្ចប់។

វគ្គសិក្សានេះប្រព្រឹត្តជាទម្រង់នៃការធ្វើបទបង្ហាញដោយនិស្សិត និងគ្រូ។ នៅពេលដែលវគ្គនេះកំពុងដំណើរការនិស្សិតនឹងមានឱកាសដើម្បីពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តរបស់សិស្សនិងការស្វែងរកដំណោះស្រាយដើម្បីលើកទឹកចិត្តសិស្សតាមរបៀបសមរម្យ។ សិក្ខាកាមនឹងឆ្លុះបញ្ចាំងវាយតម្លៃវិធីសាស្ត្រ របស់ពួកគាត់ក្នុងការបង្រៀននិងអប់រំ។ មុខវិជ្ជា**ចិត្តវិទ្យាអប់រំ** នឹងមានបង្ហាញពីគោលគំនិតចម្បងៗ គឺ៖

- ការអប់រំ និងសារៈសំខាន់នៃមុខវិជ្ជាចិត្តវិទ្យាអប់រំ
- ការយល់ពីអត្ថន័យនៃពាក្យដែលទាក់ទងនឹងមុខវិជ្ជាមុខវិជ្ជាចិត្តវិទ្យា និងសង្គមវិទ្យាអប់រំ
- តើអ្វីទៅជាគ្រូល្អ?
- តើតួនាទីរបស់ការស្រាវជ្រាវក្នុងវិស័យចិត្តវិទ្យាគឺជាអ្វី?
- តើវិធីសាស្ត្រស្រាវជ្រាវអ្វីខ្លះដែលត្រូវបានប្រើនៅក្នុងចិត្តវិទ្យាអប់រំ?
- តើខ្ញុំអាចក្លាយជាគ្រូបង្រៀនអាជីពដោយរបៀបណា?
- តើអ្វីខ្លះជាទស្សនៈនៃការអភិវឌ្ឍមនុស្ស?
- តើ Piaget មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍ពុទ្ធិ?
- តើការងាររបស់ Piaget សព្វថ្ងៃនេះត្រូវបានគេមើលឃើញយ៉ាងដូចម្ដេច?
- តើ Vygotsky មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍ពុទ្ធិ?

- តើ Erikson មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍បុគ្គលនិងសង្គម?
- តើទ្រឹស្តីនៃការអភិវឌ្ឍសីលធម៌មានអ្វីខ្លះ?
- ការអភិវឌ្ឍក្នុងវ័យកុមារភាពនិងវ័យជំទង់
  - តើកុមារអភិវឌ្ឍយ៉ាងដូចម្តេចនៅក្នុងថ្នាក់មត្តេយ្យ?
  - តើមានកម្មវិធីអប់រំកុមារតូចប្រភេទណាខ្លះ?
  - តើកុមារអភិវឌ្ឍយ៉ាងដូចម្តេចក្នុងថ្នាក់បឋម?
  - តើកុមារអភិវឌ្ឍរបៀបណានៅសាលាមធ្យមសិក្សានិងវិទ្យាល័យ?
- ទ្រឹស្តីអាកប្បកិរិយានៃការរៀន
  - តើអ្វីជាការរៀន?
  - តើទ្រឹស្តីសិក្សាអំពីអាកប្បកិរិយាមានពាក់ព័ន្ធអ្វីខ្លះ?
  - តើមានគោលការណ៍ ទ្រឹស្តីអាកប្បកិរិយា នៃការរៀនអ្វីខ្លះ?
  - តើទ្រឹស្តីសិក្សាសង្គមបានរួមចំណែកដល់ការយល់ដឹងពីការរៀនសូត្ររបស់មនុស្សដោយរបៀបណា?
- ដំណើរការព័ត៌មាននិងទ្រឹស្តីពុទ្ធិនៃការរៀន
- ការរៀបចំការបង្រៀនដើម្បីបំពេញតាមតម្រូវការរបស់សិស្ស
- គោលវិធីសិស្សមជ្ឈមណ្ឌល និងគោលវិធីស្ថាបនាចំណេះដឹង
- ការលើកទឹកចិត្តសិស្ស
- បរិស្ថានសិក្សាដែលមានប្រសិទ្ធិភាព
- ការវាយតម្លៃការរៀនសូត្ររបស់សិស្ស
- ការធ្វើតេស្តស្តង់ដា

## ៤. របាយម៉ោងសិក្សា

របាយម៉ោងសិក្សា នៃមុខវិជ្ជា**ចិត្តវិទ្យាអប់រំ** ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| សង្គមវិទ្យាអប់រំ | ១ សប្តាហ៍: សិក្សា ៣ ម៉ោង<br>៣ ម៉ោង x ១៥ សប្តាហ៍ = ៤៥ ម៉ោង/១ឆ្នាំសិក្សា ស្មើ ០៣ ក្រេឌីត |

## ៥. ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យ គ្រូបង្រៀនគប្បីត្រូវ៖

- ឱ្យអ្នកសិក្សាក្ដាប់បានពីចំណុចគន្លឹះសំខាន់ៗ នៃមេរៀនតាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ក្នុងការរៀន និងបង្រៀន ជំរុញការសិក្សាតាមបែបសកម្ម តាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវឯកសារជំនួយផ្សេងៗ។
- សម្របសម្រួលអ្នកសិក្សា ក្នុងការក្ដាប់បាននូវខ្លឹមសារមេរៀន ដោយធ្វើការវិភាគស្ថានភាព និងការពិភាក្សារកដំណោះស្រាយដើម្បីទទួលបានទាំងចំណេះ ជំនាញ និងឥរិយាបទដែលសង្គមត្រូវការ។

## ៦. ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បរមានៃចំណេះអ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗនិងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃមាន៖

- សំណួរផ្ទាល់មាត់
- កិច្ចការផ្ទះ
- កិច្ចការក្រុម
- ការឡើងធ្វើបទបង្ហាញម្នាក់ៗ ឬតាមក្រុម
- ការសួរសំណួរ ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវជាដើម។

## ៧. តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| ផ្នែកទី១៖ ចិត្តវិទ្យាអប់រំ៖ មូលដ្ឋានគ្រឹះសម្រាប់ការបង្រៀន | | |
| – តើអ្វីទៅជាគ្រូល្អ?<br>– តើតួនាទីរបស់ការស្រាវជ្រាវក្នុងវិស័យចិត្តវិទ្យាគឺជាអ្វី?<br>– តើវិធីសាស្ត្រស្រាវជ្រាវអ្វីខ្លះដែលត្រូវបានប្រើនៅក្នុងចិត្តវិទ្យាអប់រំ? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាព័ត៌មាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ | ៣ |

| | | |
|---|---|---|
| – តើខ្ញុំអាចក្លាយជាគ្រូបង្រៀនអាជីពដោយរបៀបណា? | **បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **ផ្នែកទី២៖ ទ្រឹស្តីអភិវឌ្ឍន៍** | | |
| – តើអ្វីខ្លះជាទស្សនៈនៃការអភិវឌ្ឍមនុស្ស?<br>– តើ Piaget មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍ពុទ្ធិ?<br>– តើការងាររបស់ Piaget សព្វថ្ងៃនេះត្រូវបានគេមើលឃើញយ៉ាងដូចម្តេច?<br>– តើ Vygotsky មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍ពុទ្ធិ?<br>– តើ Erikson មានទស្សនៈយ៉ាងណាចំពោះការអភិវឌ្ឍន៍បុគ្គលនិងសង្គម?<br>– តើទ្រឹស្តីនៃការអភិវឌ្ឍសីលធម៌មានអ្វីខ្លះ? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ការអភិវឌ្ឍក្នុងវ័យកុមារភាពនិងវ័យជំទង់** | | |
| – តើកុមារអភិវឌ្ឍយ៉ាងដូចម្តេចនៅក្នុងថ្នាក់មត្តេយ្យ? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុង | ៣ |

| | | |
|---|---|---|
| – តើមានកម្មវិធីអប់រំកុមារតូចប្រភេទណាខ្លះ?<br>– តើកុមារអភិវឌ្ឍយ៉ាងដូចម្ដេចក្នុងថ្នាក់បឋម?<br>– តើកុមារអភិវឌ្ឍរបៀបណានៅសាលាមធ្យមសិក្សានិងវិទ្យាល័យ? | ខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **ភាពផ្សេងៗគ្នារបស់សិស្ស(ភាពចម្រុះ)** | | |
| – តើអ្វីជាផលប៉ះពាល់នៃវប្បធម៌នៅលើការបង្រៀននិងការរៀន?<br>– តើស្ថានភាពសេដ្ឋកិច្ចសង្គមមានឥទ្ធិពលលើសមិទ្ធផលរបស់សិស្សយ៉ាងដូចម្ដេច?<br>– តើភាពខុសគ្នានៃភាសានិងកម្មវិធីសិក្សាពីរភាសាប៉ះពាល់ដល់សមិទ្ធផលរបស់សិស្សយ៉ាងដូចម្ដេច?<br>– តើការអប់រំពហុវប្បធម៌គឺជាអ្វី?<br>– តើភាពលំអៀងនៃយេនឌ័រនិងយេនឌ័រជះឥទ្ធិពល ដល់បទពិសោធនៅសាលារៀនរបស់សិស្សដោយរបៀបណា? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ផ្នែកទី៣៖ ទ្រឹស្ដីអាកប្បកិរិយានៃការរៀន** | | |
| – តើអ្វីជាការរៀន? | **វិជ្ជាសម្បទា** | ៣ |

| | | |
|---|---|---|
| – តើទ្រឹស្ដីសិក្សាអំពីអាកប្បកិរិយាមានពាក់ព័ន្ធអ្វីខ្លះ?<br>– តើមានគោលការណ៍ ទ្រឹស្ដី អាកប្បកិរិយា នៃការរៀនអ្វីខ្លះ?<br>– តើទ្រឹស្ដីសិក្សាសង្គមបានរួមចំណែកដល់ការយល់ដឹងពីការរៀនសូត្ររបស់មនុស្សដោយរបៀបណា? | – ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **ដំណើរការព័ត៌មាននិងទ្រឹស្ដីពុទ្ធិនៃការរៀន** | | |
| – តើអ្វីជាគំរូនៃដំណើរការកត់ត្រាព័ត៌មាន?<br>– ស្រាវជ្រាវលើខួរក្បាល<br>– តើអ្វីជាមូលហេតុ ដែលធ្វើឲ្យមនុស្សចងចាំឬភ្លេច?<br>– តើយុទ្ធសាស្ត្រនៃការចងចាំអាចបង្រៀនយ៉ាងដូចម្ដេច?<br>– តើអ្វីអ្វីខ្លះធ្វើឲ្យព័ត៌មានន័យសំខាន់?<br>– តើយុទ្ធសាស្ត្រសិក្សាអ្វីខ្លះដែលជួយសិស្សរៀន?<br>– តើយុទ្ធសាស្ត្រនៃទ្រឹស្ដីពុទ្ធិអាចជួយសិស្សរៀនយ៉ាងដូចម្ដេច? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ផ្នែកទី៤៖ មេរៀនដែលមានប្រសិទ្ធភាព** | | |
| – តើអ្វីជាវិធីបង្រៀនផ្ទាល់? | **វិជ្ជាសម្បទា** | ៣ |

| | | |
|---|---|---|
| – តើវិធីបង្រៀនផ្ទាល់អនុវត្តយ៉ាងដូចម្តេច?<br>– តើការស្រាវជ្រាវបានផ្តល់ការណែនាំលើការប្រើប្រាស់វិធីបង្រៀនផ្ទាល់យ៉ាងដូចម្តេច?<br>– តើសិស្សរៀននិងផ្ទេរគំនិតដោយរបៀបណា?<br>– តើការពិភាក្សាត្រូវបានប្រើក្នុងបង្រៀនយ៉ាងដូចម្តេច? | – ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **គោលវិធីសិស្សមជ្ឈមណ្ឌល និងគោលវិធីស្ថាបនាចំណេះដឹង** | | |
| – តើអ្វីជាទស្សន ស្ថាបនាចំណេះដឹងចំពោះការរៀន?<br>– តើការរៀនបែបសហការត្រូវបានប្រើក្នុងការបង្រៀនយ៉ាងដូចម្តេច?<br>– តើត្រូវបង្រៀនវិធីដោះស្រាយបញ្ហានិងជំនាញគិត យ៉ាងដូចម្តេច? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ការរៀបចំការបង្រៀនដើម្បីបំពេញតាមតម្រូវការរបស់សិស្ស** | | |
| | **វិជ្ជាសម្បទា** | ៣ |

| | | |
|---|---|---|
| – តើអ្វីខ្លះជាធាតុនៃការបង្រៀនដែលមានប្រសិទ្ធភាពលើសពីមេរៀនល្អ?<br>– តើសិស្សត្រូវបានដាក់ជាក្រុមដើម្បីបំពេញនូវភាពខុសគ្នារវាងសមិទ្ធផល?<br>– តើអ្វីទៅជាការរៀនពូកែ )Mastery learning)?<br>– តើមានវិធីណាខ្លះក្នុងការបង្រៀនជាលក្ខណៈបុគ្គល? | – ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **ការលើកទឹកចិត្តសិស្ស** | | |
| – តើអ្វីជាការលើកទឹកចិត្ត?<br>– តើទ្រឹស្តីនៃការលើកទឹកចិត្តមានអ្វីខ្លះ?<br>– តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីពង្រឹងការលើកទឹកចិត្តផ្អែកលើសមិទ្ធផល?<br>– តើគ្រូបង្រៀនអាចបង្កើនការលើកទឹកចិត្តរបស់សិស្សក្នុងការរៀនដូចម្តេច?<br>– តើគ្រូបង្រៀនអាចផ្តល់រង្វាន់លើលទ្ធផល ការខិតខំប្រឹងប្រែង និងភាពរីកចម្រើនយ៉ាងដូចម្តេច? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ផ្នែកទី៥៖ បរិស្ថានសិក្សាដែលមានប្រសិទ្ធិភាព** | | |

| | | |
|---|---|---|
| – តើអ្វីជាបរិស្ថានសិក្សាដែលមានប្រសិទ្ធភាព?<br>– តើអ្វីជាផលប៉ះពាល់នៃពេលវេលាទៅលើការរៀនសូត្រ?<br>– តើការអនុវត្តអ្វីខ្លះរួមចំណែកធ្វើឱ្យការគ្រប់គ្រងថ្នាក់មានប្រសិទ្ធិភាព?<br>– តើអ្វីខ្លះជាយុទ្ធសាស្ត្រខ្លះសម្រាប់គ្រប់គ្រង អាកប្បកិរិយាខុសឆ្គង?<br>– តើការបែងចែកអាកប្បកិរិយាត្រូវបានប្រើដើម្បីគ្រប់គ្រងបញ្ហាអាកប្បកិរិយាខុសឆ្គងធ្ងន់ធ្ងរយ៉ាងដូចម្ដេច?<br>– តើធ្វើដូចម្ដេចដើម្បីទប់ស្កាត់បញ្ហាអាកប្បកិរិយា? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្រ្តបង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្ដីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |
| **ការវាយតម្លៃការរៀនសូត្ររបស់សិស្ស** | | |
| – តើអ្វីខ្លះជាគោលបំណងបង្រៀន និងរបៀប ប្រើប្រាស់គោលបំណងបងៀន?<br>– តើការរៀនសូត្ររបស់សិស្សត្រូវបានគេវាយតម្លៃយ៉ាងដូចម្ដេច?<br>– តើត្រូវបង្កើតតេស្តយ៉ាងដូចម្ដេច?<br>– តើអ្វីទៅជាការវាយតម្លៃបែបពិតប្រាកដ )authentic portfolio និងសកម្មភាព? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្ដីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្រ្តបង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា** | ៣ |

| | | |
|---|---|---|
| – តើចំណាត់ថ្នាក់ត្រូវកំណត់ដោយរបៀបណា? | – យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | |
| **ការធ្វើតេស្តស្តង់ដារ** | | |
| – តើអ្វីទៅជាតេស្តស្តង់ដារ និងតេស្តស្តង់ដារ ត្រូវបានប្រើដោយរបៀបណា?<br>– តើតេស្តស្តង់ដាប្រភេទណាខ្លះត្រូវបានប្រើ?<br>– តើតេស្តតាមស្តង់ដារត្រូវបានបកស្រាយដូចម្តេច?<br>– តើមានបញ្ហាអ្វីខ្លះទាក់ទងនឹងការធ្វើតេស្តស្តង់ដារនិងការប្រើតេស្តក្នុងថ្នាក់រៀន? | **វិជ្ជាសម្បទា**<br>– ពង្រឹងការយល់ដឹងទូលំទូលាយអំពីទ្រឹស្តីអភិវឌ្ឍន៍ពុទ្ធិ អាកប្បកិរិយា លំនាំនៃការកត់ត្រាពតមាននៅក្នុងខួរក្បាល ការសម្របសម្រួលរបៀបរៀន និងវិធីសាស្ត្របង្រៀន ការលើកទឹកចិត្តសិស្សនៅក្នុងវិស័យអប់រំ<br>**បំណិនសម្បទា**<br>– អភិវឌ្ឍជំនាញច្នៃប្រឌិត បង្កើតបរិស្ថានសិក្សាសមស្រប វាយតម្លៃលទ្ធផលសិក្សាក្នុងការបង្រៀននិងអប់រំ យ៉ាងមានប្រសិទ្ធភាព<br>**ចរិយាសម្បទា**<br>– យកទ្រឹស្តីទាំងនេះទៅអនុវត្ត ដោះស្រាយបញ្ហាប្រចាំថ្ងៃដែលកើតឡើងក្នុងលំនាំនៃការរៀននិងការបង្រៀន ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ | ៣ |

## ៨. ឯកសារយោង

**Reading Materials:**

Robert E. Slavin., (2009 ). *Educational Psychology*: Theory and Practice. Pearson Education, Inc.

**Additional Materials:**

1. Woolfolk A., (2004) *Educational Psychology*. Pearson Education, Inc.
2. Santrock 5th, Educational psychology
3. World Wide Web resources on Educational Psychology

# កម្មវិធីសិក្សាលម្អិតមុខវិជ្ជាៈ សង្គមវិទ្យាអប់រំ
# សម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

---

## ១. សេចក្តីផ្តើម

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ ដោយឈរលើគោលនយោបាយចំនួន ២គឺ (១) ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ដើម្បីលើកកម្ពស់ឱកាសក្នុងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលនយោបាយទាំងពីរខាងលើ ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ស្តីពី **សង្គមវិទ្យាអប់រំ** ព្រោះមុខវិជ្ជានេះជួយឱ្យអ្នកដឹកនាំការងារអប់រំទទួលបានពុទ្ធិវិទ្យាសាស្រ្តដែលជួយឱ្យយើងអាចពិពណ៌នា ពន្យល់ និងព្យាករណ៍ពីបាតុភូតសង្គមបានយ៉ាងត្រឹមត្រូវ និងពិតប្រាកដ។ យើងអាចយកពុទ្ធិវិទ្យាសាស្រ្តដែលបានមកពីការសិក្សាបាតុភូតសង្គមតាមបែបសង្គមវិទ្យា មកប្រើប្រាស់ដើម្បីបង្កើតជាគោលនយោបាយ និងច្បាប់សម្រាប់ការគ្រប់គ្រងបាតុភូតសង្គម និងកែប្រែបាតុភូត អវិជ្ជមាន ដូចជាទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយបញ្ហាសង្គមដ៏មានប្រសិទ្ធិភាព និងប្រសិទ្ធិផល ដើម្បីឈានទៅអភិវឌ្ឍន៍សង្គមឱ្យកាន់តែប្រសើរឡើង។ យើងក៏អាចយកពុទ្ធិវិទ្យាសាស្រ្តដែលបានមកពីការសិក្សាបាតុភូតសង្គមតាមបែបសង្គមវិទ្យា មកប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនសម្រាប់ការរស់នៅក្នុងសង្គមប្រកបដោយសុភមង្គល។ សង្គមវិទ្យា គឺជាវិធីនៃការគិតអំពីពិភពលោកនិងកន្លែងរស់នៅរបស់យើង។ នេះវាគឺជារបៀបវិភាគមួយ។ ក្នុងន័យនេះការគិតថាសង្គមវិទ្យាមានន័យថាធ្វើឱ្យអ្នកស្គាល់ - អ្វីដែលយើង "ដឹង" អ្វីដែលយើងអាចទទួលបានពីការអប់រំ។ បញ្ហាប្រឈមនៃការវិភាគរបស់យើង គឺដើម្បីស្វែងយល់អំពីរបៀបដែលសាលារៀន និងការសិក្សាភ្ជាប់ទៅភ្នាក់ងារបុគ្គលអន្តរកម្មសង្គម និងរចនាសម្ព័ន្ធសង្គមធំៗ។ មុខវិជ្ជានេះ នឹងគ្របដណ្តប់លើការអភិវឌ្ឍ និងការអនុវត្តគំនិតសង្គម និងទស្សនវិស័យទាក់ទងនឹងបញ្ហា ដូចជា ការអប់រំនិងសង្គមនីយកម្ម វប្បធម៌ យុវវ័យ យេនឌ័រក្នុងការអប់រំ ដំណើរការនៃការជ្រើសរើសការសិក្សា ការងារនិងការសិក្សា អប់រំការបែងចែកសង្គម និងសង្គមជាដើម។

## ២. គោលបំណង

មុខវិជ្ជា**សង្គមវិទ្យាអប់រំ** នឹងមានបង្ហាញពីគោលគំនិតចម្បងៗ គឺ (១) ការអប់រំ និងសារៈសំខាន់នៃការអប់រំ (២) សង្គមវិទ្យា និង (៣) សង្គមវិទ្យាអប់រំ សម្រាប់អ្នកដឹកនាំការងារអប់រំ ព្រមទាំងបំបែកទៅជាមេរៀនតូចៗជាច្រើនទៀត។ ដូច្នេះក្រោយពីការសិក្សាលើមុខវិជ្ជានេះចប់ អ្នកសិក្សានឹងអាចៈ

| | |
|---|---|
| **វិជ្ជាសម្បទា** | – យល់ដឹងច្បាស់ពីអត្ថន័យនៃពាក្យការអប់រំ សង្គមវិទ្យា សង្គមវិទ្យាអប់រំ វប្បធម៌។<br>– យល់ដឹងពីការវិវត្ត និងប្រវត្តិមុខវិជ្ជាសង្គមវិទ្យា សង្គមវិទ្យាអប់រំ<br>– យល់ច្បាស់ពីសារប្រយោជន៍នៃការសិក្សាពីសង្គមវិទ្យា សង្គមវិទ្យាអប់រំ<br>– យល់ដឹងពីបញ្ញត្តិអប់រំ ទ្រឹស្តីសង្គមវិទ្យា សង្គមវិទ្យានៃការអប់រំ<br>– យល់ពីប្រវត្តិ និងប្រភេទសង្គម ពីការវិវត្ត នៃសង្គមរស់នៅរបស់មនុស្ស<br>– យល់អំពីទស្សនៈសង្គមវិទ្យានៃការពិតដែលជាការស្ថាបនាសង្គម<br>– ស្វែងយល់ពីភាពខុសគ្នារវាងទ្រឹស្តីចិត្តសាស្ត្រនិងសង្គមវិទ្យានៃការអភិវឌ្ឍផ្ទាល់ខ្លួន<br>– យល់ដឹងអំពីដំណើរការនៃការអភិវឌ្ឍសីលធម៌<br>– យល់ដឹងពីសារៈសំខាន់នៃការធ្វើទំនាក់ទំនងសង្គមសម្រាប់បុគ្គលនិងសង្គម<br>– រៀនពីតួនាទីរបស់ក្រុមគ្រួសារ និងក្រុមមនុស្សក្នុងសង្គម<br>– យល់ពីរបៀបដែលយើងត្រូវធ្វើសង្គមនីយកម្មតាមរយៈស្ថាប័នជាផ្លូវការ ដូចជាសាលារៀនកន្លែងធ្វើការ និងរដ្ឋាភិបាល<br>– យល់ពីរបៀបដែលមនុស្សធ្វើសង្គមនីយកម្មចូលក្នុងតួនាទីថ្មីនៅចំណុចអន្តរកាលទាក់ទងនឹងអាយុ<br>– ពិពណ៌នាអំពីពេលណានិងរបៀបដែលការរស់រានមានជីវិតកើតឡើង<br>– យល់ច្បាស់ពីការធ្វើណាត់ថ្នាក់សកល<br>– យល់ដឹងពីរបៀបនៃប្រព័ន្ធការធ្វើចំណាត់ថ្នាក់ផ្សេងៗគ្នាបានអភិវឌ្ឍន៍<br>– យល់ពាក្យបច្ចេកទេសចេញពីប្រព័ន្ធរបស់ពិភពលោក Wallerstein<br>– ស្វែងយល់ពីការចាត់ថ្នាក់នៃសេដ្ឋកិច្ចរបស់ធនាគារពិភពលោក<br>– ស្វែងយល់ពីភាពខុសគ្នានៃចំណាត់ថ្នាក់ភាពក្រីក្រ<br>– យល់ដឹងពីស្ថានភាពសេដ្ឋកិច្ចនៃតំបន់ក្រីក្របំផុតក្នុងពិភពលោក |

| | |
|---|---|
| | – យល់ដឹងពីផលប៉ះពាល់អវិជ្ជមាននៃភាពក្រីក្រ<br>– ស្វែងយល់ពីទស្សនវិស័យទំនើបភាវូបនីយកម្មនិងទ្រឹស្តីលើការបែងចែកជាសកល<br>– ស្វែងយល់ពីភាពខុសគ្នារវាងភេទ និងយេនឌ័រ<br>– ស្វែងយល់ពីអត្ថន័យនៃអត្តសញ្ញាណមនុស្សប្តូរយេនឌ័រ ប្តូរភេទ និងអត្តសញ្ញាណភេទដូចគ្នា<br>– យល់ដឹងពីយេនឌ័រ ចេញពីទស្សនវិស័យនៃសង្គមវិទ្យានីមួយៗ<br>– យល់ពីឥរិយាបថខុសៗ គ្នាដែលទាក់ទងនឹងយេនឌ័រ  និងផ្លូវភេទ<br>– ស្វែងយល់ពីភាពខុសគ្នារវាងអំណាចនិងរដ្ឋអំណាច<br>– យល់ដឹងពីអត្តសញ្ញាណ និងអំពីសិទ្ធិអំណាចបីប្រភេទ<br>– យល់ដឹងពីនិយមន័យទូទៅនៃរដ្ឋាភិបាលដូចជា រាជាធិបតេយ្យ បក្សពួកនិយម របបផ្តាច់ការ និងប្រជាធិបតេយ្យ<br>– ស្វែងយល់ពីទម្រង់ទូទៅនៃរដ្ឋាភិបាលនិងកំណត់អត្តសញ្ញាណជាក់ស្តែងនៃជីវិតនីមួយៗ<br>– យល់ដឹងពីសារៈសំខាន់នៃ "មនុស្សម្នាក់ៗការបោះឆ្នោតមួយ" ក្នុងការកំណត់គោលនយោបាយសហរដ្ឋអាមេរិក<br>– ស្វែងយល់ពីឥទ្ធិពលនៃជាតិសាសន៍ យេនឌ័រ  និងបញ្ហាថ្នាក់ៗ ស្តីពីដំណើរការបោះឆ្នោតយល់អំពីរបៀបដែលទ្រឹស្តីរចនាសម្ព័ន្ធមុខងារនិយម ទ្រឹស្តីបដិសំឃោគ និងទ្រឹស្តីអន្តរកម្មនិមិត្តសញ្ញា មានទស្សនៈចំពោះ  រដ្ឋាភិបាល និងនយោបាយ<br>– យល់ពីអត្ថន័យនៃសង្គមវិទ្យានៃការអប់រំ<br>– ស្វែងយល់ពីវិសាលភាពនៃសង្គមវិទ្យានៃការអប់រំ<br>– យល់ដឹងពីការបែងចែករវាងសង្គមវិទ្យាសង្គមនិងសង្គមវិទ្យាអប់រំ<br>– យល់ពីតម្រូវការដើម្បីសិក្សាសង្គមវិទ្យានៃការអប់រំ<br>– ស្វែងយល់ពីមុខងារនៃការអប់រំនៅក្នុងសង្គម<br>– ស្វែងយល់ពីវិធីសាស្រ្តប្រព័ន្ធចំហដើម្បីការអប់រំ<br>– យល់ពីអត្ថន័យនៃសង្គមនីយកម្មជំនាញវិជ្ជាជីវៈនៃគ្រូបង្រៀន<br>– ស្វែងយល់ពីដំណាក់និងវគ្គសង្គមនីយកម្មវិជ្ជាជីវៈរបស់គ្រូបង្រៀន<br>– ស្វែងយល់ពីបញ្ហាការងារ និងអង្គភាពនៅក្នុងសង្គមនីយកម្មជំនាញវិជ្ជាជីវៈនៃគ្រូបង្រៀន |

| | |
|---|---|
| | – យល់ដឹងពីទំនាក់ទំនងរបស់គ្រូបង្រៀនជាមួយអ្នកគ្រប់គ្រង មិត្តរួមការងារ សិស្សនិងអាណាព្យាបាល។<br>– យល់ដឹងពីអត្ថន័យនៃបែងចែកសង្គម<br>– ស្វែងយល់ពីប្រភេទ (categories) នៃការបែងចែកសង្គម<br>– យល់ដឹងពីឥទ្ធិពលនៃការបែងចែកលើជីវិតរបស់បុគ្គល និងក្រុម<br>– យល់ដឹងពីដំណើរការ និងមូលហេតុនៃការបែងចែកសង្គម<br>– យល់ដឹងពីប្រភេទ (types) នៃការបែងចែកសង្គម<br>– យល់ដឹងពីម៉ូដែលសេរីនិងចែកចាយនៃយុត្តិធម៌សង្គម<br>– ស្វែងយល់ពីសមភាពនៃឱកាសសិក្សា<br>– យល់ដឹងពីស្តង់ដារខុសគ្នានៃស្ថាប័នអប់រំ<br>– យល់ដឹងពីការអប់រំនិងអាហារូបករណ៍<br>– យល់ដឹងពីការស្មើភាពគ្នានៃឱកាសអប់រំ<br>– យល់ពីបញ្ហានានាទាក់ទងនឹងសមភាពនៃឱកាសក្នុងវិស័យអប់រំ<br>– ស្វែងយល់ពីកម្មវិធីអប់រំ ថ្នាក់រៀនពង្រឹងបន្ថែម<br>– យល់ដឹងពីការអភិវឌ្ឍន៍ការយល់ដឹង លើការ ការអាន គណិតវិទ្យា<br>– ស្វែងយល់ពីការអប់រំជាសិទ្ធិ និងជាធាតុមួយនៃការបែងចែកសង្គម<br>– យល់ដឹងពីចំណេះដឹង និងការអភិវឌ្ឍចំណេះដឹង<br>– ស្វែងយល់ពីលទ្ធផលសង្គមសេដ្ឋកិច្ច<br>– យល់ដឹងពីលក្ខខណ្ឌការងារ<br>– យល់ដឹងពីការចូលរួមសង្គម និងការគាំទ្រ<br>– យល់ដឹងពីភាពរឹងមាំផ្នែកចិត្តសាស្ត្រ<br>– យល់ដឹងពីសុខភាពផ្លូវកាយ និងសុខមាលភាព<br>– ស្វែងយល់ពីផលប៉ះពាល់គ្រួសារ<br>– យល់ពីតម្លៃនៃការប្រើប្រាស់ពេលវេលា<br>– យល់ពីទំនាក់ទំនងរវាងការអប់រំ និងវប្បធម៌<br>– យល់ពីផលប៉ះពាល់នៃវប្បធម៌នៅលើវិស័យអប់រំ<br>– យល់ពីឥទ្ធិពលនៃការអភិវឌ្ឍវិស័យអប់រំ<br>– យល់ពីទំនាក់ទំនងរវាងសេដ្ឋកិច្ចនិងការអប់រំ |

| | |
|---|---|
